**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០០៥ សាបក

ថ្ងៃ ពុធ ១៤កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី ពិធីប្រកាសជាផ្លូវការដាក់ឱ្យអនុវត្ត ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥

នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ក្រសួងទេសចរណ៍ និងគណៈកម្មការអន្តរក្រសួងដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍនវិស័យទេសចរណ៍ខេត្តសៀមរាប បានរៀបចំពិធីប្រកាស**ជាផ្លូវការដាក់ឱ្យអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងជាតំណាងដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមប្រព័ន្ធវីដេអូ ដោយមានការចូលរួមពី **ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ចំនួន៤២០នាក់។**

**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥** ត្រូវបានរាជរដ្ឋាភិបាលអនុម័តជាផ្លូវការ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។ ផែនការមេនេះបានរៀបចំចងក្រងឡើងដោយ**"គណៈកម្មការអន្តរក្រសួងដើម្បីសិក្សារៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប"** ដឹកនាំដោយ**ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួង។

ការរៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបនេះ នឹងក្លាយជាយន្តការដ៏មានសារៈសំខាន់ចាំបាច់ សម្រាប់ការឆ្លើយតបទៅនឹងស្ថានភាពនាពេលបច្ចុប្បន្នក៏ដូចជាអនាគត ដោយមាន**បំណងប្រាថ្នា ចំនួន ០៣ គឺ÷**

**បំណងប្រាថ្នាទី១÷** សៀមរាបគឺជាខេត្តទេសចរណ៍អន្តរជាតិដ៏គួរឱ្យចាប់អារម្មណ៍ និងមានការទទួលស្គាល់លក្ខណៈជាសកលលើការអភិរក្ស និងកិច្ចគាំពារសម្បត្តិបេតិកភណ្ឌវប្បធម៌ និងបរិស្ថានធម្មជាតិ ដោយផ្តល់ជូននូវធនធានទេសចរណ៍ និងភាពទាក់ទាញជាច្រើនទៀត។

**បំណងប្រាថ្នាទី២÷** ធានាឱ្យបានផលប្រយោជន៍សេដ្ឋកិច្ច-សង្គមជាអតិបរមាពីវិស័យទេសចរណ៍ ពោលគឺតំបន់ប្រវត្តិសាស្ត្រអង្គរ តំបន់ទីក្រុងដែលមានស្ទឹងសៀមរាប តំបន់ទន្លេសាប ឧទ្យានជាតិភ្នំគូលែន និងតំបន់ជនបទដែលជាគោលដៅទេសចរណ៍ត្រូវតែភ្ជាប់ជាមួយការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

**បំណងប្រាថ្នាទី៣÷** ខេត្តសៀមរាបត្រូវតែជាគោលដៅទេសចរណ៍មានគុណភាព សំដៅទាក់ទាញភ្ញៀវទេសចរមកកម្សាន្តបានម្តងហើយម្តងទៀត និងភ្ញៀវទេសចរកម្រិតខ្ពស់អាច បង្កើននូវចំណូលជូនប្រជាពលរដ្ឋមូលដ្ឋាន និងកសាងសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយបរិយាបន្ន។

ដើម្បីឆ្លើយតបនឹងបំណងប្រាថ្នាខាងលើទាំង ០៣ ខាងលើ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ មានគោលបំណងធ្វើឱ្យខេត្តសៀមរាបក្លាយជាគោលដៅទេសចរណ៍ដ៏ចម្បង និងទាក់ទាញនៅក្នុងតំបន់ និងសកលលោក ដោយឈរលើមូលដ្ឋាននៃសម្បត្តិបេតិកភណ្ឌវប្បធម៌ ធម្មជាតិ ប្រវត្តិសាស្ត្រ សាសនា និងភាពជាខ្មែរ។ ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងបរិយាបន្ន ខេត្តសៀមរាបគួររៀនសូត្រពីគំរូអនុវត្តល្អៗពីគ្រប់សម័យកាល ពិសេសសម័យអង្គរ ក៏ដូចជាការផ្តោតលើ "**ភាពស្អាត បៃតង និងឆ្លាត**" ក្នុងបរិការណ៍សម័យទំនើប និងដំណើរឆ្ពោះទៅការកសាងសេដ្ឋកិច្ចឌីជីថល។ ទន្ទឹមនេះ គោលបំណងយុទ្ធសាស្ត្រ ដែលនឹងដាក់ចេញដោយផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥ មានចំនួន ០៣ ដែលបំពេញឱ្យគ្នាទៅវិញទៅមក៖ **(១)-ទេសចរណ៍ប្រកបដោយគុណភាពខ្ពស់, (២)-ទេសចរណ៍ឆ្លាត និង (៣)-ទេសចរណ៍ដែលមានតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានវប្បធម៌ និងបរិស្ថានធម្មជាតិ។**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ផែនការមេដាក់ចេញគោលដៅយុទ្ធសាស្ត្រ **ចំនួន ០៧ គឺ** (១)- ការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាពនៅខេត្តសៀមរាប, (២)- ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ, (៣)- ការផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍មកខេត្តសៀមរាប, (៤)- ការពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប, (៥)- ការគ្រប់គ្រងបរិស្ថាននៅខេត្តសៀមរាប, (៦)- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍នៅខេត្តសៀមរាប និង (៧)- ការពង្រឹងអភិបាលកិច្ចសម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍ នៅខេត្តសៀមរាបដោយឈរលើអភិក្រមនៃការចូលរួម។ ផែនការមេនេះ ដាក់ចេញនូវ **យុទ្ធសាស្ត្រសរុបចំនួន ៤៣ សកម្មភាពអនុវត្តសរុបចំនួន ១៣៥** សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង អមជាមួយគម្រោងសកម្មភាពអាទិភាព ចំនួន ២០។

នាឱកាសពិធីប្រកាសជាផ្លូវការនេះ ក្នុងនាមរាជរដ្ឋាភិបាល **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ បានដាក់ចេញនូវអនុសាសន៍គន្លឹះចំនួន ០៤ សម្រាប់អនុវត្តរយៈពេលខ្លី ពីចុងឆ្នាំ២០២១ ដល់ ឆ្នាំ២០២៣ រួមមាន៖

**ទី១).** បន្តរៀបចំយន្តការស្ថាប័ន ដោយត្រូវរៀបចំបង្កើត "**គណៈកម្មការគ្រប់គ្រង និង អភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**" ឱ្យបានឆាប់ ដើម្បីដឹកនាំសម្របសម្រួល និង ត្រួតពិនិត្យការអភិវឌ្ឍគោលដៅទេសចរណ៍ខេត្តសៀមរាប។ បន្ទាប់មក, គណៈកម្មការនេះត្រូវបង្កើត "**អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍**" តាមតំបន់អាទិភាពទាំង ៦ រួមមាន តំបន់ឧទ្យានជាតិភ្នំគូលែន, តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី, តំបន់អង្គរ, តំបន់ក្រុងសៀមរាប, តំបន់បឹងទន្លេសាប និង តំបន់ទេសចរណ៍សៀមរាបថ្មី។ ចំពោះ **អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បេតិកភណ្ឌអង្គរ** គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរជាតិអប្សរា។

**ទី២).** ស្នើឱ្យគ្រប់ភាគីពាក់ព័ន្ធប្រកាន់យកស្មារតីម្ចាស់ការ រួមគិត រួមធ្វើ រួមទទួលខុសត្រូវ ក្នុងការអនុវត្តផែនការសកម្មភាពនៃផែនការមេនេះ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងវិធានការយុទ្ធសាស្ត្រដែលបានដាក់ចេញ ជាពិសេស សកម្មភាពអនុវត្តនានា ក្នុងរយៈពេលខ្លី និង មធ្យម។

**ទី៣).** ទាំងអស់គ្នាត្រូវចូលរួមអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវ **នីតិវិធីប្រតិបត្តិស្តង់ដា, វិធានសុវត្ថិភាពទេសចរណ៍ និង វិធានការណែនាំនានា** ទាំងវិធានការសុខាភិបាល, វិធានការរដ្ឋបាល, វិធានការច្បាប់, និងវិធានការអប់រំ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

ទី៤). ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរខេត្ត ត្រូវរួមគ្នាពង្រឹងលក្ខណៈសម្បត្តិរបស់ខេត្តសៀមរាបក្នុងការទាក់ទាញភ្ញៀវទេសចរផ្ទៃក្នុង និង ភ្ញៀវទេសចរអន្តរជាតិ តាមរយៈ÷

- ការជំរុញបញ្ចប់ **គម្រោងកែលម្អផ្លូវ ៣៨ ខ្សែ** ក្នុងក្រុងសៀមរាប រួមជាមួយការរៀបចំបន្ថែមនូវផ្លូវថ្មើរជើង ផ្លូវសម្រាប់រថយន្តទេសចរណ៍ ផ្លូវសម្រាប់ម៉ូតូ ផ្លូវជិះកង់ បង្គោល និងអំពូលភ្លើងបំភ្លឺសាធារណៈ រួមទាំងសម្បទាអមសងខាងផ្លូវ
- ការពន្លឿន **ការអភិវឌ្ឍកំពង់ផែចុងឃ្នាស** ឱ្យស្របតាមស្តង់ដាកំពង់ផែទេសចរណ៍ ដោយផ្តោតលើការបំពាក់សម្បទាទ្រទ្រង់សេវាកម្ម និងផលិតផលទេសចរណ៍ថ្មីៗបន្ថែម
- ការពង្រឹងនូវការគ្រប់គ្រងលំហូរភ្ញៀវក្នុងតំបន់អង្គរ ស្របតាមគន្លងប្រក្រតីភាពថ្មី ដោយត្រូវរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា (SOP), ជំរុញពិពិធកម្ម និង ផ្សព្វផ្សាយផលិតផល និង សេវាកម្ម ទេសចរណ៍ថ្មីៗ នៅក្នុងតំបន់អង្គរ ដូចជា ការរៀបចំទេសភាពបៃតងនៅក្នុងតំបន់ប្រាសាទជាដើម
- ការពន្លឿននូវការសាងសង់ **"អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ"** ដើម្បីឈានទៅបង្កើនសមត្ថភាពផ្ទុកសម្រាប់អ្នកដំណើរតាមផ្លូវអាកាស មកកាន់គោលដៅ ខេត្តសៀមរាប
- លើកទឹកចិត្តដល់ការបន្តនិតន្តអភិវឌ្ឍន៍ក្រុងសៀមរាប និងគោលដៅអាទិភាពទាំងអស់ជា **"ក្រុងទេសចរណ៍ឆ្លាត"** និង **"គោលដៅទេសចរណ៍ឆ្លាត"** សំដៅលើកកម្ពស់គុណភាពជីវិត និងសុខុមាលភាពប្រជាពលរដ្ឋកាន់តែល្អប្រសើរ និងចីរភាពនៃការអភិវឌ្ឍស្របតាមចក្ខុវិស័យនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ក៏ដូចជាទិសដៅអភិវឌ្ឍនៅក្នុងក្របខណ្ឌអាស៊ាន, ទាំងលើផ្នែកភាពហេដ្ឋារចនា-សម្ព័ន្ធរឹង និងទន់, ប្រព័ន្ធសន្តិសុខ និងសុវត្ថិភាព និង ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ជាដើម។

ជារួម **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥** មានគោលដៅធ្វើឱ្យ **ខេត្តសៀមរាបអាចក្តាប់យកមកវិញនូវមោទនភាពជាគោលដៅទេសចរណ៍ចម្បងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ីអាគ្នេយ៍** ក្នុងរយៈពេលមធ្យម និងវែងខាងមុខ។ ទន្ទឹមនេះ ការដាក់ឱ្យអនុវត្ត**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥** នឹងគាំទ្រដល់ការត្រៀម**ខ្លួនបើកទទួលទេសចរណ៍វ៉ាក់សាំង និងការជំរុញចលនាទេសចរណ៍ផ្ទៃក្នុង។** ផែនការគន្លឹះទាំងនេះ នឹងចូលរួមស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា នៅក្នុងក្របខណ្ឌទូទាំងប្រទេស, ជាពិសេស នៅខេត្តសៀមរាបនេះផ្ទាល់តែម្តង, ដោយឆាប់រហ័ស ព្រមទាំងអាចចាប់យកកាលានុវត្តភាពពីវិបត្តិកូវីដ-១៩ ដើម្បីដាក់ចេញនូវការកែទម្រង់ស៊ីជម្រៅ សំដៅប្រែក្លាយកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព, សុវត្ថិភាព និងចីរភាព ដែលនឹងផ្តល់ផ្លែផ្កាចូលរួមទ្រទ្រង់ ដល់ការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចពីវិបត្តិជំងឺ កូវីដ-១៩ ផងដែរ។

ជាទីបញ្ចប់ ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្ត **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥"** ចាប់ពីពេលនេះតទៅ ៕